ការជំនុំជម្រះ

## ប្រសិនបើលោកអ្នកមានសំណួរ សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈ:

**(+855) 023 861 525**
**RESOURCE.CENTRE@ECCC.GOV.KH**

**ឬអាចមកកាន់ការិយាល័យរបស់យើងដោយផ្ទាល់**
នៅអគារលេខ៤០ មហាវិថីសហព័ន្ធរុស្ស៊ី(វិថី១១០)
ទីក្រុងភ្នំពេញ

**តាមគេហទំព័រ** www.eccc.gov.kh

**ស្វែងយល់បន្ថែមតាមរយៈ:**

@krtribunal

@krtribunal2

@eccckh

t.me/eccckh

**សៀវភៅស្វែងយល់អំពី អ.វ.ត.ក.**

ការជំនុំជម្រះ

អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

# ព័ត៌មានសង្ខេប អំពី អ.វ.ត.ក.




មានសវនាការចំនួន **៦៣៩** ថ្ងៃ នៅក្នុងសាលសវនាការ អ.វ.ត.ក.

មានសាក្សី និងអ្នកជំនាញចំនួន **២១៨**រូបបានផ្ដល់សក្ខីកម្មនៅក្នុងសាលសវនាការ



ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន **១១៦**រូប បានផ្ដល់ភ័ស្ដុតាង និងថ្លែងអំពីព្យសនកម្មរបស់ពួកគាត់



សាលក្រម សាលដីកា សេចក្ដីសម្រេច និងដីការបស់អង្គជំនុំជម្រះច្រើនជាង **១៣៤៥** ត្រូវបានអនុម័ត

មានបណ្ដុំឯកសារច្បាប់ច្រើនជាង **២៣២ ០០០** ជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង

សំណងចំនួន **២៦** ត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង



មានសាធារណជនចំនួន **២៤៤ ៦៦៨** នាក់ បានមកទស្សនាសវនាការដោយផ្ទាល់

*ការប្រកាសទោស និងការផ្ដន្ទាទោស ពាក់ព័ន្ធនឹង**អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** និង**ឧក្រិដ្ឋកម្មសង្គ្រាម**។*

# អំឡុងពេលជំនុំជម្រះក្ដី



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ត្រូវបានបង្កើតឡើងក្រោមច្បាប់របស់កម្ពុជា និងអនុវត្តការងារក្រោមការគាំទ្រពីអង្គការសហប្រជាជាតិ ដើម្បីជំនុំជម្រះក្ដីលើអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**ដំណាក់កាលជំនុំជម្រះក្ដីរបស់ អ.វ.ត.ក. បានប្រព្រឹត្តទៅពីឆ្នាំ២០០៧ ដល់ឆ្នាំ២០២២។**




ទីតាំងឧក្រិដ្ឋកម្មប្រមាណ **១០០** នៅទូទាំងប្រទេសកម្ពុជាត្រូវបានស៊ើបអង្កេត

បុគ្គល**១០**រូប ត្រូវបានស៊ើបអង្កេត



ជនរងគ្រោះចំនួន **៣៩៥៩**នាក់ បានចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ និងសំណុំរឿង០០២

ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន **៦៤២២** ត្រូវបានទទួលយក សម្រាប់បណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៣ សំណុំរឿង០០៤ សំណុំរឿង០០៤/១ និងសំណុំរឿង០០៤/២

## ការងារទាំងនោះរួមមាន៖

- **ការផ្សព្វផ្សាយព័ត៌មាន** អំពី អ.វ.ត.ក. ទៅសាធារណជន
- **ឆ្លើយតបទៅនឹងសំណើសុំចូលមើលឯកសារ** របស់សាធារណជន
- ការការពារ**សាក្សី** និង**ជនរងគ្រោះ**
- ត្រួតពិនិត្យមើលការអនុវត្ត ការផ្តល់**សំណង**ដែលបានផ្តល់ឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណី
- ថែទាំ រក្សាទុក និងគ្រប់គ្រង**បណ្ណសារ**
- ការពិនិត្យ និងធ្វើ**ចំណាត់ថ្នាក់**ឯកសារឡើងវិញ



**អគារមុខងារសេសសល់**
មហាវិថីសហព័ន្ធរុស្សី (វិថី ១១០) ភ្នំពេញ

# ក្រោយការជំនុំជម្រះ

បន្ទាប់ពីបញ្ចប់ការជំនុំជម្រះក្តី រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានឯកភាពគ្នាបន្តអនុវត្តការងារទាក់ទងនឹង **ការរក្សាកេរដំណែលរបស់ អ.វ.ត.ក.។**



**អគារសវនាការ**
ទីតាំងចាស់ នៅជាប់នឹងបញ្ជាការដ្ឋាន
កងទ័ពជើងគោក នៅចោមចៅ

**សហករណ៍ និងការដ្ឋាន៖** គោលបំណងនៃការជម្លៀសប្រជាជនពីទីក្រុងដើម្បីបង្ខំឱ្យទៅធ្វើការនៅសហករណ៍ និងការដ្ឋាន គឺដើម្បីបង្កើនកសិផលជាតិ និងបំពេញគោលដៅសេដ្ឋកិច្ចដែលថា ត្រូវអភិវឌ្ឍប្រទេសឱ្យរីកចម្រើនរុងរឿង និងប្រែក្លាយប្រជាជនទៅជាសង្គមកម្មករ និងកសិករ។

**មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស៖** នៅជាង ២០០ កន្លែងនៅទូទាំងប្រទេស ប.ក.ក. បានអនុវត្តគោលនយោបាយឧក្រិដ្ឋកម្មនៃការកំណត់អត្តសញ្ញាណ ការចាប់ខ្លួន ការដាក់ឱ្យនៅឯកា និង “ការកម្ទេច” (សម្លាប់) ខ្មាំង ដែលប្រព្រឹត្តខុសធ្ងន់ធ្ងរ ចំណែកជនដែលប្រព្រឹត្តកំហុសតិចតួច ដែលគេសន្មត់ថាជា “សមាសភាពមិនល្អ” ត្រូវបានអប់រំកែប្រែតាមរយៈការបំពាក់បំប៉ននយោបាយ ការទិតៀន-ស្វ័យទិតៀន និងការចាត់តាំងការងារធ្វើឡើងដើម្បីលត់ដំអ្នកដែលមាននិន្នាការប្រឆាំងបដិវត្តន៍។

**ក្រុមគោលដៅ៖** ដូចដែលបានរកឃើញដោយ អ.វ.ត.ក. ខ្មែរក្រហមធ្វើទុក្ខបុកម្នេញក្រុមជាក់លាក់ និងជនជាតិភាគតិច ដែលត្រូវបានយល់ថាជាខ្មាំងសតិអារម្មណ៍៖ ពុទ្ធសាសនិកជន ជនជាតិចាមវៀតណាម អតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរនិងក្រុមគ្រួសាររបស់ពួកគេ និងប្រជាជនថ្មី (ប្រជាជននៅទីក្រុង) និងក្រុមផ្សេងៗទៀត។

**ការរៀបអាពាហ៍ពិពាហ៍៖** ប.ក.ក. បានអនុវត្តគោលនយោបាយឧក្រិដ្ឋកម្ម ដើម្បីរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបង្ខំឱ្យរួមសង្វាស ដើម្បីបង្កើនចំនួនប្រជាជនកម្ពុជា ក្នុងការកសាងប្រទេស ការពារប្រឆាំងនឹងសត្រូវ និងការផ្លាស់ប្តូរសង្គម។

**ប្រជាជនចន្លោះពី ១.៥ ទៅ ២ លាននាក់** ត្រូវបានសន្និដ្ឋានថាបានស្លាប់នៅក្នុងរបបខ្មែរក្រហម ដោយសារភាពអត់ឃ្លាន ការធ្វើការងារហួសកម្លាំង ការធ្វើទារុណកម្ម ឬត្រូវបានសម្លាប់។

# អង្គហេតុសំខាន់ៗ

**ខ្មែរក្រហម៖** ចលនាដែលដឹកនាំប្រទេសកម្ពុជា ក្រោមការគ្រប់គ្រងរបស់បក្សកុម្មុនីស្តកម្ពុជា (ប.ក.ក.)

**បដិវត្តន៍៖** គោលដៅរបស់ខ្មែរក្រហម គឺដើម្បីអនុវត្តបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា តាមរយៈ «មហាលោតផ្លោះ មហាអស្ចារ្យ» ដែលរៀបចំឡើងដើម្បីកសាងការពារប្រទេសពីសំណាក់ខ្មាំង និងកែប្រែប្រជាជនទាំងស្រុងឱ្យក្លាយទៅជាសង្គមខ្មែរដែលមិនមានសាសនា និងរួបរួមគ្នាមួយមានតែវណ្ណៈកម្មករ-កសិករ។

**ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩៖** ខ្មែរក្រហមបានគ្រប់គ្រងប្រទេសកម្ពុជាក្នុងអំឡុងពេលនោះ ហើយពួកគេបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតរួមមានការជម្លៀសប្រជាជនចេញពីទីក្រុង និងតាមភូមិដ្ឋាននានា ការបង្ខំឱ្យធ្វើការងារហួសកម្លាំង និងការធ្វើបាបនៅតាមការដ្ឋាន និងសហករណ៍ ការចាប់ខ្លួន ការធ្វើទារុណកម្ម ការបាត់ខ្លួន និងការសម្លាប់ ការរៀបការដោយបង្ខំ និងការរើសអើងចំពោះក្រុមប្រជាជនផ្សេងៗ ដែលខ្មែរក្រហមបានចាត់ទុកថាជាសត្រូវ។

**ភូមិភាគ៖** ដើម្បីគ្រប់គ្រងប្រទេសឱ្យបានពេញលេញ ខ្មែរក្រហមបានបែងចែកប្រទេសកម្ពុជាជាភូមិភាគ (ដូចជា ភូមិភាគឧត្តរ ឦសាន បូព៌ា និរតី បស្ចិម ពាយ័ព្យ) ហើយបានបំបែកបន្ថែមទៀតទៅជាស្រុក ឃុំ និងភូមិ។

**ការបណ្តេញចេញ និងជម្លៀសប្រជាជនចេញពីទីលំនៅ៖** នៅពេលដណ្តើមអំណាចគ្រប់គ្រងប្រទេសកម្ពុជាបានជោគជ័យ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនិងទីប្រជុំជនផ្សេងទៀត ដើម្បីទៅធ្វើការនៅសហករណ៍ និងការដ្ឋាននានា ដើម្បីបង្កបង្កើនផលដំណាំដែលចាំបាច់ ។

អង្គហេតុសំខាន់ៗ



សំណុំរឿង ០០២

# នួន ជា

**តើគាត់ជានរណា?** អនុលេខាបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក.) ប្រធានសភាតំណាងប្រជាជន និងជានាយករដ្ឋមន្ត្រីស្តីទីបណ្តោះអាសន្ននៃរបបកម្ពុជាប្រជាធិបតេយ្យ។

**តើគាត់ត្រូវបានកាត់ទោសអំពីអ្វី?** ដាក់ពន្ធនាគារអស់មួយជីវិតសម្រាប់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ គាត់បានស្លាប់ក្នុងអំឡុងពេលមានពិរុទ្ធភាព។

- បង្កើត អនុវត្តផែនការឧក្រិដ្ឋកម្មរបស់ ប.ក.ក.
- បញ្ជាឱ្យបោសសម្អាត និងសម្លាប់ខ្មាំងនៅទូទាំងប្រទេស
- រៀបចំផែនការដើម្បីជម្លៀសប្រជាជនក្នុងទ្រង់ទ្រាយធំពីទីក្រុងភ្នំពេញ និងកន្លែងផ្សេងទៀត។
- ចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនៅសហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខ រួមទាំងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

## តើអ្នកដឹងទេ?

គាត់ត្រូវបានរកឃើញថាមានពិរុទ្ធពីបទប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម និងជនជាតិចាមនៅក្នុងប្រទេសកម្ពុជា និងការធ្វើទុក្ខបុកម្នេញលើក្រុមមនុស្សផ្សេងទៀត រួមទាំងពុទ្ធសាសនិក អតីត មន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេ។





សំណុំរឿង ០០១

# កាំង ហ្គេកអ៊ាវ (ហៅ ឌុច)

**តើគាត់ជានរណា?** ប្រធានមន្ទីរសន្តិសុខ ស-២១ នៅក្នុងទីក្រុងភ្នំពេញ។

**តើគាត់ត្រូវបានកាត់ទោសអំពីអ្វី?** ជាប់ពន្ធនាគារអស់មួយជីវិត ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១។

- បានជួយបង្កើតមន្ទីរសន្តិសុខ ស-២១ រៀបចំមុខងារ និងអនុវត្តសិទ្ធិ អំណាចលើបុគ្គលិកទាំងអស់។
- បណ្តុះបណ្តាលអ្នកសួរចម្លើយឱ្យប្រើអំពើហិង្សាលើរូបកាយនិងផ្លូវចិត្តលើអ្នកទោស
- លើកទឹកចិត្ត ផ្តល់ជំនួយ និងជំរុញដល់បុគ្គលិករបស់គាត់ ទោះបីដឹងថា សកម្មភាពរបស់គាត់ដែលប្រព្រឹត្តនោះជាបទឧក្រិដ្ឋកម្មក៏ដោយ។

## តើអ្នកដឹងទេ?

មន្ទីរ ស-២១ គឺជាកន្លែងសម្រាប់ឃុំខ្លួន សួរចម្លើយ និងសម្លាប់អ្នកដែលគេយល់ថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា។ មានបុគ្គលមិនតិចជាង ១២ ២៧៣ នាក់ ត្រូវបានឃុំខ្លួន ហើយយ៉ាងហោចណាស់មានបុគ្គលចំនួន ១១ ៧៤២ ត្រូវបានសម្លាប់។

អៀង សារី

## សំណុំរឿង០០២

# អៀង សារី



**តើគាត់ជានរណា?** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ។

**តើគាត់ត្រូវបានចោទប្រកាន់ពីបទអ្វីខ្លះ?** អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅសហករណ៍ ការដ្ឋាន និង មន្ទីរសន្តិសុខ។

### តើអ្នកដឹងទេ?

រួមជាមួយនឹង ប៉ុល ពត នួន ជា ខៀវ សំផន និងអ្នកផ្សេងទៀត អៀង សារី ត្រូវបានចោទប្រកាន់៖

- ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅសហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរើសអើងប្រឆាំងនឹងអ្នកដែលគេយល់ឃើញថាជាខ្មាំងរបស់ ប.ក.ក.
- បង្កើតគោលការណ៍ ប.ក.ក. ដើម្បីកម្ទេចខ្មាំង និងត្រួតពិនិត្យបញ្ហាសន្តិសុខផ្ទៃក្នុង

### តើលទ្ធផលចុងក្រោយទៅយ៉ាងដូចម្តេច?

ដំណើរការជំនុំជម្រះក្តីលើ អៀង សារី ត្រូវបានបញ្ចប់ បន្ទាប់ពីគាត់ទទួលអនិច្ចកម្ម។

## សំណុំរឿង០០២

# ខៀវ សំផន



**តើគាត់ជានរណា?** ប្រធាននៃគណៈប្រធានរដ្ឋរបបកម្ពុជាប្រជាធិបតេយ្យ (ប្រមុខរដ្ឋ)។

**តើគាត់ត្រូវបានកាត់ទោសអំពីអ្វី?** ជាប់ពន្ធនាគារអស់មួយជីវិតពីបទអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។

- បង្កើត និងអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់ ប.ក.ក. ដែលបានបណ្តាលឱ្យប្រជាជនកម្ពុជាទទួលរងភាពអត់ឃ្លាន ។
- បានដឹងអំពីការបោសសម្អាតទ្រង់ទ្រាយធំ ស្ថានភាពរស់នៅដ៏លំបាករបស់ប្រជាជន កង្វះអាហារ និងជំងឺ ហើយមិនបានអន្តរាគមន៍ដើម្បីកែលម្អលក្ខខណ្ឌទាំងនោះ បើទោះបីជាគាត់មានតួនាទីជាមេដឹកនាំជាន់ខ្ពស់ក៏ដោយ
- ចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនៅសហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខ រួមទាំងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

### តើអ្នកដឹងទេ?

គាត់ត្រូវបានគេរកឃើញថាមានពិរុទ្ធពីបទអំពើប្រល័យពូជសាសន៍ប្រឆាំងជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា និងការធ្វើទុក្ខបុកម្នេញលើក្រុមប្រជាជនផ្សេងៗទៀត រួមទាំងពុទ្ធសាសនិក និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេ។

ខៀវ សំផន



សំណុំរឿង០០៣

## មាស មុត

**តើគាត់ជានរណា?** មេបញ្ជាការកងទ័ពជើងទឹកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (កងពលលេខ ១៦៤) ក្នុងចំណោមតួនាទីផ្សេងៗទៀត។

**តើមានការចោទប្រកាន់អ្វីខ្លះ?** លោក មាស មុត ត្រូវបានគេចោទថាជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តន៍កម្ពុជា ជាពិសេសលើដែនសមុទ្រ កោះ និងកំពង់ផែសមុទ្រនៃប្រទេសកម្ពុជា។

### តើលទ្ធផលចុងក្រោយទៅយ៉ាងដូចម្តេច?

សហចៅក្រមស៊ើបអង្កេតមិនបានឯកភាពគ្នា ថាតើបទចោទប្រឆាំងនឹង មាស មុត គួរតែបញ្ជូនទៅជំនុំជម្រះ ឬយ៉ាងណា។ ដូច្នោះនីតិវិធីប្រឆាំងរូបគាត់ត្រូវបានបញ្ចប់ ដោយមិនបានបញ្ជូនគាត់ទៅជំនុំជម្រះក្តីទេ។



សំណុំរឿង០០២

## អៀង ធីរិទ្ធ

**តើគាត់ជានរណា?** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ។

**តើគាត់ត្រូវបានចោទប្រកាន់ពីបទអ្វីខ្លះ?** គាត់ត្រូវបានចោទប្រកាន់ពីបទអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅសហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខ។

### តើអ្នកដឹងទេ?

រួមជាមួយនឹង ប៉ុល ពត នួន ជា ខៀវ សំផន អៀង សារី និងអ្នកផ្សេងទៀត អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់:

- មានទំនួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម រួមទាំងដោយការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ និងការរើសអើងប្រឆាំងនឹងអ្នកដែលគេយល់ថាជាខ្មាំងរបស់ ប.ក.ក.
- ដឹងអំពីស្ថានភាពរស់នៅដ៏លំបាក កង្វះអាហារ និងជំងឺ ហើយមិនបានធ្វើអន្តរាគមន៍ដើម្បីកែលម្អស្ថានភាពនោះ បើទោះបីជាគាត់មានតួនាទីជាមន្ត្រីជាន់ខ្ពស់ហើយក្តី

### តើលទ្ធផលចុងក្រោយទៅយ៉ាងដូចម្តេច?

អៀង ធីរិទ្ធ ត្រូវបានរកឃើញថា មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមជំនុំជម្រះក្តី ហើយនីតិវិធីចោទប្រកាន់លើរូបគាត់ត្រូវបានបញ្ចប់ បន្ទាប់ពីគាត់ទទួលមរណៈភាព។

អ៊ឹម ចែម

## សំណុំរឿង០០៤/១

# អ៊ឹម ចែម



**តើគាត់ជានរណា?** លេខាស្រុកព្រះនេត្រព្រះ ក្នុងតំបន់ ៥ (ភូមិភាគពាយ័ព្យ)។

**តើគាត់ត្រូវបានចោទប្រកាន់អ្វីខ្លះ?** អ៊ឹម ចែម ត្រូវបានចោទថាជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។

**តើលទ្ធផលចុងក្រោយទៅយ៉ាងដូចម្តេច?**

សហចៅក្រមស៊ើបអង្កេតបានបញ្ចប់នីតិវិធីប្រឆាំងលើអ្នកស្រី អ៊ឹម ចែម ព្រោះគាត់ត្រូវបានសន្មតថាមិនស្ថិតនៅក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនោះទេ និងមិនត្រូវនាំគាត់មកជំនុំជម្រះក្តីក្រោមច្បាប់ អ.វ.ត.ក. ឡើយ។

## សំណុំរឿង០០៣

# ស៊ូ ម៉េត



**តើគាត់ជានរណា?** មេបញ្ជាការកងទ័ពអាកាសនៃរបបកម្ពុជាប្រជាធិបតេយ្យ (កងពលលេខ ៥០២)។

**តើគាត់ត្រូវបានចោទប្រកាន់ពីបទអ្វីខ្លះ?** លោក ស៊ូ ម៉េត ត្រូវបានគេចោទថាជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជា ជាពិសេសក្នុងពេលបោសសម្អាតកងពលលេខ ៥០២ និងភូមិភាគបូព៌ា។

**តើលទ្ធផលចុងក្រោយទៅយ៉ាងដូចម្តេច?**

លោក ស៊ូ ម៉េត ត្រូវបានកំណត់ជាជនសង្ស័យ ប៉ុន្តែគាត់បានស្លាប់ក្នុងពេលស៊ើបអង្កេតដោយតុលាការ។ ដូច្នេះ ដំណើរការនីតិវិធីប្រឆាំងនឹងគាត់ត្រូវបានបញ្ចប់។

ស៊ូ ម៉េត

យឹម ទិត្យ

## សំណុំរឿង០០៤/១

# យឹម ទិត្យ



**តើគាត់ជានរណា?** លេខាតំបន់ ១, ៣, ៤ (ភូមិភាគពាយ័ព្យ) និងតំបន់១៣ (ភូមិភាគនិរតី) និងលេខាស្រុកគិរីវង់។

**តើគាត់ត្រូវបានចោទប្រកាន់ពីបទអ្វីខ្លះ?** យឹម ទិត្យ ត្រូវបានចោទថាជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។

### តើលទ្ធផលចុងក្រោយយ៉ាងដូចម្តេច?

សហចៅក្រមស៊ើបអង្កេតមិនបានឯកភាពគ្នា ថាតើបទចោទប្រឆាំងនឹង យឹម ទិត្យ គួរតែបញ្ជូនទៅជំនុំជម្រះ ឬយ៉ាងណា។ ដូច្នោះនីតិវិធី ប្រឆាំងរូបគាត់ត្រូវបានបញ្ចប់ ដោយមិនបានបញ្ជូនគាត់ទៅជំនុំជម្រះក្តីទេ។

អោ អាន

## សំណុំរឿង០០៤/២

# អោ អាន



**តើគាត់ជានរណា?** លេខាតំបន់ ៤១ មុនពេលដែលលោកត្រូវបានតែងតាំងជាអនុលេខាតំបន់ភូមិភាគកណ្តាល។

**តើគាត់ជាប់ពាក់ព័ន្ធបទចោទអ្វីខ្លះ?** ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងក្នុងតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់។

### តើលទ្ធផលចុងក្រោយយ៉ាងដូចម្តេច?

សហចៅក្រមស៊ើបអង្កេតមិនបានឯកភាពគ្នា ថាតើបទចោទប្រឆាំងនឹង អោ អាន គួរតែបញ្ជូនទៅជំនុំជម្រះ ឬយ៉ាងណា។ ដូច្នោះនីតិវិធីប្រឆាំងរូបគាត់ត្រូវបានបញ្ចប់ ដោយមិនបានបញ្ជូនគាត់ទៅជំនុំជម្រះក្តីទេ។

# សក្ខីកម្ម

“ ខ្ញុំបាទមិនដែលនឹកស្រម៉ៃថា ខ្ញុំបាទបានមកអង្គុយបកស្រាយនៅមុខអង្គសវនាការក្នុងថ្ងៃនេះទេដើម្បីពិពណ៌នាអំពីទុក្ខលំបាករបស់ខ្ញុំដល់ក្មេងជំនាន់ក្រោយ និងមនុស្សទូទៅ។ ខ្ញុំបាទមានកិត្តិយសក្រៃលែង ខ្ញុំបាទអត់ចង់មានបានអ្វីទេ វត្ថុដែលខ្ញុំចង់បាន គឺរបស់ដែលមើលមិនឃើញ គឺវាជាយុត្តិធម៌មួយសម្រាប់អ្នកដែលបានស្លាប់ទៅ។ ”

*ប្រតិចារឹកថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩*
*ឯកសារលេខ E1/39.1*



**លោក វ៉ាន់ ណាត**

“ ខ្ញុំមិនដែលនឹកស្មានថា ខ្ញុំមានឱកាសដូចថ្ងៃនេះទេ។ ប៉ុន្តែពេលនេះ ខ្ញុំសប្បាយចិត្តចំពោះតុលាការនេះ ហើយខ្ញុំសង្ឃឹមថាតុលាការនេះ នឹងផ្តល់យុត្តិធម៌ដល់រូបនាងខ្ញុំ និងប្រជាជនកម្ពុជាទាំងអស់ផងដែរ។នាងខ្ញុំមានតែជំងឺផ្លូវចិត្តបៀមទុក្ខជាយូរអង្វែងមកហើយ មិនដឹងថ្លែងវាចាប្រាប់នរណាថា អ្វីល្អអ្វីអាក្រក់ ខ្ញុំដឹងថាប្រជាជនទាំងអស់ជាជនរងគ្រោះ ប៉ុន្តែតិចនិងច្រើនតែងតែមានហើយ។ ហើយនាងខ្ញុំសង្ឃឹមថា តុលាការនេះជួយរកយុត្តិធម៌ តើអ្វីល្អអ្វីអាក្រក់ តើវិបត្តិផ្លូវចិត្តរបស់ប្រជាជន និងតំណាងនាងខ្ញុំ តំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ និងបានជាស្បើយពីជម្ងឺផ្លូវចិត្ត។ ”

*ប្រតិចារឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២*
*លេខឯកសារ E1/136.1*



**លោកស្រី យឹម សុវណ្ណ**



# សមិទ្ធផល

## តើការជំនុំជម្រះក្តីបានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ប្រជាជនកម្ពុជា?



- ធ្វើការស៊ើបអង្កេតយ៉ាងហ្មត់ចត់ ដើម្បីបង្ហាញឱ្យឃើញរូបភាពច្បាស់លាស់នៅក្នុងសម័យកាលដ៏វិនាសកម្មបំផុតនៃប្រវត្តិសាស្ត្ររបស់កម្ពុជា។



- ផ្ញើសារដ៏សំខាន់ ក្នុងការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព ដោយប្រកាន់យកគោលការណ៍ដែលថា អ្នកដែលប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម នឹងត្រូវទទួលខុសត្រូវចំពោះអំពើដ៏ឃោរឃៅនោះ



- ចងក្រងសក្ខីកម្មរបស់ជនរងគ្រោះ តំណាងឱ្យកំណត់ត្រាសាធារណៈ ដែលមិនអាចលុបបំបាត់បាននូវអំពើឃោរឃៅទាំងឡាយ និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ



- លើកកម្ពស់ដំណើរការព្យាបាលផ្លូវចិត្តសម្រាប់ជនរងគ្រោះដែលរស់រានមានជីវិត




- បង្កើតបានជាតុលាការគំរូតែមួយគត់សម្រាប់ផ្តល់យុត្តិធម៌អន្តរកាល

## ការស្តារនីតិសម្បទា

ផ្តល់ឱកាសឱ្យអ្នករស់រានមានជីវិតទាមទារសេចក្តីថ្លៃថ្នូររបស់ពួកគេឡើងវិញ។ តាមរយៈការទទួលស្គាល់ផលប៉ះពាល់ ដែលពួកគេបានទទួលរង និងការឈឺចាប់ដែលពួកគេបន្តស៊ូទ្រាំ ហើយរឿងរ៉ាវរបស់ជនរងគ្រោះត្រូវបានសង្គមទទួលស្គាល់និងយល់កាន់តែច្បាស់ដែលរួមចំណែកដល់ការព្យាបាលផ្លូវចិត្តនៅក្នុងសង្គម។



*ក្រុមជួយខ្លួនឯង*

## ការចងក្រងឯកសារ និងការអប់រំ

រក្សា និងស្វែងយល់ឱ្យស៊ីជម្រៅអំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម និងជួយទប់ស្កាត់ការកើតឡើងម្តងទៀតនៃអំពើឃោរឃៅនៅក្នុងប្រទេសកម្ពុជា និងកន្លែងផ្សេងៗទៀត។

*អេប-កម្មវិធីសិក្សា ប្រវត្តិសាស្ត្រខ្មែរក្រហម*



**សំណងទាំងអស់មាននៅទីនេះ**



# សំណង

## សំណងសមូហភាព និងសំណងផ្លូវចិត្តចំនួន ២៦ គម្រោង

- គំនិតផ្តួចផ្តើមសង្គម និងវប្បធម៌
- ស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី
- អនុម័តដោយ អ.វ.ត.ក.
- ផ្តល់មូលនិធិ និងអនុវត្តដោយសង្គមស៊ីវិល និងអង្គភាពសាធារណៈផ្សេងៗ

### តើសំណងសម្រាប់ធ្វើអ្វី?

- ទទួលស្គាល់ភាពឈឺចាប់របស់ជនរងគ្រោះ

- ផ្តល់សំណងជានិមិត្តរូបសម្រាប់ផលប៉ះពាល់ដែលបង្កឡើងដោយរបបខ្មែរក្រហម

**“ គំនិតផ្តួចផ្តើមមានចេតនាជម្រុញដល់ការលើកកម្ពស់ការសិក្សា និងយល់ដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម ដើម្បី លើកកម្ពស់វប្បធម៌សន្តិភាព និងរួមចំណែកដល់ ”**

*សាលក្រមសំណុំរឿង ០០២/០១, កថាខ័ណ្ឌទី ១១៥២*

## សំណងមានចំនួន៣ប្រភេទ

### ការចងចាំ

គោរពវិញ្ញាណក្ខន្ធអ្នកស្លាប់និងផ្តល់តម្លៃជនរងគ្រោះដែលនៅរស់រានមានជីវិត។ វាអនុញ្ញាតឱ្យយើង ធ្វើការរម្លឹកអំពីអតីតកាលដោយច្បាស់លាស់។

*ការចងក្រង និងការបោះពុម្ពផ្សាយសេចក្តីថ្លែងការណ៍របស់ឌុច អំពីការសុំទោស និងការទទួលស្គាល់ចំពោះការទទួលខុសត្រូវរបស់គាត់*



## នៅក្នុងមជ្ឈមណ្ឌលធនធាន លោកអ្នកអាចៈ

សិក្សា ស្រាវជ្រាវ អានសៀវភៅ ឬធ្វើកិច្ចការផ្សេងៗនៅក្នុង**ការិយាល័យ** ដែលមានសៀវភៅច្រើនជាង ១៨០០ក្បាល ទាំងសៀវភៅអេឡិចត្រូនិច បណ្ណុំឯកសារច្បាប់អន្តរជាតិ មានអិនធឺណិត មានកុំព្យូទ័រ និងតុសម្រាប់អនុវត្តកិច្ចការផ្សេងៗផងដែរ។

ពិនិត្យមើល**ឯកសារដើមរបស់តុលាការ**នៅក្នុងបណ្ណសារជាមួយនឹងការជួយសម្រួលពីបុគ្គលិកដ៏ជំនាញរបស់ អ.វ.ត.ក.។

ប្រើប្រាស់ទីតាំងនេះសម្រាប់សិក្ខាសាលា សវនាការត្រាប់ សន្និសីទ ឬបទបង្ហាញផ្សេងៗនៅក្នុង**សាលពហុបំណង**។



## បទពិសោធន៍តាមអនឡាញ

បើទោះបីជាអ្នកមិនអាចមកដល់មជ្ឈមណ្ឌលធនធាននេះ ក៏ដោយ ប៉ុន្តែអ្នកនៅតែអាចចូលប្រើប្រាស់ឯកសាររបស់យើងបាននៅគ្រប់ទីកន្លែងដែលអ្នកកំពុងស្ថិតនៅ។

គេហទំព័រ **www.eccc.gov.kh** មានរក្សាទុកឯកសារយ៉ាងច្រើន ដូចជាបណ្ណសារ ការទស្សនាបន្ទប់សវនាការទូរនិម្មិត ស្វែងយល់ពីការវិវដ្តនៃប្រវត្តិសាស្ត្រតាមឆ្នាំនីមួយៗ អត្ថបទព័ត៌មាន វីដេអូប្រវត្តិសាស្ត្រ ការផ្តល់សក្ខីកម្ម និងប្រតិចារឹកផ្សេងៗ។

# មជ្ឈមណ្ឌលធនធាន

## កន្លែងតែមួយ ប៉ុន្តែមានធនធានច្រើន

- តើអ្នកចង់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហមឬទេ?
- តើអ្នកជាសិស្ស និស្សិត ឬជាអ្នកស្រាវជ្រាវអំពីច្បាប់អន្តរជាតិ ប្រវត្តិសាស្ត្រ ឬវិទ្យាសាស្ត្រសង្គម មែនទេ?
- តើអ្នកចង់ដឹងពីរបៀបដែលបណ្ណសារទំនើបដំណើរការដែរឬទេ?
- តើអ្នកចង់គោរពដល់ជនរងគ្រោះ និងសិក្សាស្វែងយល់រឿងរ៉ាវពាក់ព័ន្ធបន្ថែមទៀតឬទេ?

មជ្ឈមណ្ឌលធនធាន គឺជាកន្លែងផ្តល់ព័ត៌មានរបស់ អ.វ.ត.ក.។ មជ្ឈមណ្ឌលនេះ ត្រូវបាន**បំពាក់ដោយបច្ចេកវិទ្យាទំនើប មានភាពទាក់ទាញ និងងាយស្រួលប្រើប្រាស់** មានទីតាំងស្ថិតនៅកណ្តាលទីក្រុងភ្នំពេញ ដែលលោកអ្នកអាចមកប្រើប្រាស់ធនធាននៅទីនេះដោយសេរី និង ជារៀងរាល់ថ្ងៃ។





## នៅក្នុងបណ្ណសារ អ.វ.ត.ក. មាន៖

- ឯកសារសំណុំរឿងទាំងអស់
- ឯកសារសរុបច្រើនជាង **២៣៣ ០០០** ឯកសារ
- ឯកសារសរុបជិត **២.៤** លាន ទំព័រ
- ដីកា និងសេចក្តីសម្រេចច្រើនជាង **៣២ ០០០** ច្បាប់
- ប្រតិចារឹកចំនួន **៦៧០** ច្បាប់
- បណ្តុំភស្តុតាងរាប់ម៉ឺនច្បាប់
- ឯកសារមាន **៣** ភាសា (ខ្មែរ អង់គ្លេស និងបារាំង)
- ឯកសារថតជាវីដេអូ និងថតជាសម្លេង ច្រើនជាង **១១ ០០០** ម៉ោង
- ឯកសារមិនមែនជាឯកសារច្បាប់ **រាប់ពាន់**ប្រភេទ

## តើខ្ញុំអាចចូលទៅប្រើប្រាស់ឯកសារក្នុងបណ្ណសារនោះបានយ៉ាងដូចម្តេច?

### ការស្រាវជ្រាវឯកសារដោយផ្ទាល់

សំណុំឯកសារសាធារណៈ: ទាំងអស់មាននៅក្នុងមជ្ឈមណ្ឌលធនធាន អ.វ.ត.ក. នៅក្នុងទីក្រុងភ្នំពេញ។






### តាមគេហទំព័រ

ស្វែងរកឯកសារតាមតំណរ
**archive.eccc.gov.kh**

**ត្រូវការព័ត៌មានបន្ថែម**
**សូមសួរទៅកាន់បណ្ណារក្សរបស់យើងតាមរយៈ:**
archive@eccc.gov.kh

បណ្ណសារ

# បណ្ណសារ

## បណ្ណសារគឺជាកេរដំណែលដ៏សំខាន់បំផុតរបស់ អ.វ.ត.ក.

ឯកសារអំពីការស៊ើបអង្កេត ការជំនុំជម្រះក្តី និងបណ្តឹងសារទុក្ខផ្សេងៗ រួមនឹងភស្តុតាង និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ត្រូវបានតម្កល់ទុកក្នុងបណ្ណសារទាំងអស់។

**ការគ្រប់គ្រង ការរៀបចំ និងការរក្សាទុក** ក្នុងទម្រង់ជាឯកសារក្រដាស និងជាឯកសារអេឡិចត្រូនិច។

ការចងក្រងប្រវត្តិសាស្ត្រឱ្យមានតម្លៃ គឺជា**បេតិកភណ្ឌវប្បធម៌**របស់កម្ពុជា។



## តើអ្នកដឹងទេ?

ឯកសារនៅក្នុងបណ្ណសាររបស់ អ.វ.ត.ក. ត្រូវបានចងក្រងជាឯកសារអេឡិចត្រូនិចទាំងអស់ ហើយត្រូវបានរៀបចំទុកដាក់តាមបទដ្ឋានអន្តរជាតិ ដើម្បី ផ្តល់ភាពងាយស្រួលសម្រាប់មនុស្សជំនាន់ក្រោយសិក្សាស្រាវជ្រាវ។



បណ្ណសារ

## សម្ភារៈ និងធនធានដែលមានសារៈសំខាន់ផ្សេងៗ៖

- **សៀវភៅណែនាំ និងសេចក្ដីអត្ថាធិប្បាយច្បាប់អំពី អ.វ.ត.ក.** នឹងពន្យល់លោកអ្នកតាមរយៈការអនុវត្តការងារ និងដំណើរការជំនុំជម្រះក្ដី នៅក្នុង អ.វ.ត.ក.
- **គន្ថនិទ្ទេស** បញ្ជីនៃការបោះពុម្ពផ្សាយពាក់ព័ន្ធនឹង អ.វ.ត.ក.
- **សន្ទានុក្រម** បីភាសា ទាក់ទងនឹងពាក្យច្បាប់ បច្ចេកទេស និងពាក្យដែលប្រើក្នុងបរិបទខ្មែរក្រហម
- **បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១** ដែលចងក្រងដោយ អ.វ.ត.ក. ក្នុងអំឡុងពេលស៊ើបអង្កេតផ្អែកតាមឯកសារប្រវត្តិសាស្ត្រ
- **បញ្ជីរាយមាតិកា អ.វ.ត.ក.** ដែលរួមមានសេចក្ដីសង្ខេបរបស់សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី ថ្នាក់ដឹកនាំនៅក្នុង អ.វ.ត.ក. ព្រមទាំងប្រវត្តិសង្ខេបរបស់មេដឹកនាំខ្មែរក្រហមជាច្រើនរូបផងដែរ។

## បរិបទប្រវត្តិសាស្ត្រ

- **រចនាសម្ព័ន្ធមេដឹកនាំខ្មែរក្រហម** បង្ហាញពីឋានានុក្រមរបស់មេដឹកនាំខ្មែរក្រហមនៅក្នុងប្រព័ន្ធសម្ងាត់ ក្នុងជួរបក្ស រដ្ឋ យោធា និងរដ្ឋបាលភូមិភាគ។
- **ផែនទីទីតាំងឧក្រិដ្ឋកម្ម** ដែលត្រូវបានស៊ើបអង្កេតដោយ អ.វ.ត.ក. ក្នុងសំណុំរឿងទាំងអស់។
- **ផែនទីបង្ហាញការជម្លៀសប្រជាជន** មុនពេល និងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ
- **ផែនទីបង្ហាញការកាន់កាប់របស់ខ្មែរក្រហម** លើទឹកដីកម្ពុជាពីឆ្នាំ ១៩៧០ ដល់ថ្ងៃទី១៧ មេសា ១៩៧៥

## គេហទំព័រ

**គេហទំព័ររបស់ អ.វ.ត.ក. គឺជាចំណុចគោលដើម្បីចូលទៅកាន់បណ្ណាសារ ឯកសារអប់រំ និងឯកសារអេឡិចត្រូនិចផ្សេងៗ។**

**WWW.ECCC.GOV.KH**

មានឯកសារជាភាសា៖ **ខ្មែរ** | **អង់គ្លេស** | **បារាំង**

- **អ្វីដែលអ្នកគួរដឹង** មូលដ្ឋានគ្រឹះអំពីការបង្កើត និងដំណើរការអនុវត្តការងាររបស់ អ.វ.ត.ក. ព្រមទាំងសាលសវនាការទូរនិម្មិត
- **ព័ត៌មានអំពីសំណុំរឿង** ទាក់ទងនឹងការស៊ើបអង្កេត ការជំនុំជម្រះក្ដី និងបណ្ដឹងសាទុក្ខផ្សេងៗ
- **បណ្ណសារ** ចូលទៅប្រើប្រាស់ឯកសារសាធារណៈនៃសំណុំរឿងដោយផ្ទាល់
- **បណ្ណាំឯកសារអេឡិចត្រូនិច** ជាកន្លែងប្រមូលផ្ដុំឯកសារទាំងអស់ដែលត្រូវបានបោះពុម្ពផ្សាយ និងមាតិកាពហុព័ត៌មានផ្សេងៗ។



## មជ្ឈមណ្ឌលធនធានចល័តរបស់ អ.វ.ត.ក.

### តើរថយន្តក្រុងនេះជាអ្វី?

រថយន្តក្រុងនេះ គឺជាមជ្ឈមណ្ឌលធនធានចល័តរបស់ អ.វ.ត.ក.។ វាធ្វើដំណើរក្នុងប្រទេសកម្ពុជា ហើយចូលចតនៅគ្រប់ខេត្តទាំងអស់។

### តើអ្នកណាអាចប្រើប្រាស់រថយន្តក្រុងនេះបាន?

រថយន្តក្រុងនេះ និងធនធានដែលមាននៅក្នុងរថយន្តក្រុងនេះ គឺសម្រាប់អ្នករាល់គ្នា និងជាពិសេស៖ ប្រជាជនកម្ពុជា ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះអ្នករស់រានមានជីវិត សិស្ស និស្សិត និងអង្គការនានា។

### តើអ្វីជាវត្ថុបំណងរបស់រថយន្តក្រុងនេះ?

- **ការចូលរួម** និងការផ្តល់ជូននូវទីកន្លែងសម្រាប់សន្ទនាគ្នា ជាពិសេសគឺការសន្ទនាអន្តរជំនាន់
- **ការផ្សព្វផ្សាយ និងការអប់រំ** អំពី អ.វ.ត.ក. និងការចូលរួមចំណែករបស់ អ.វ.ត.ក. ក្នុងការផ្តល់សំណង និងគាំទ្រលើកិច្ចការទាំងឡាយ។
- **ស្តាប់** ពីប្រជាពលរដ្ឋទូទៅ រួមទាំងយុវជនជំនាន់ក្រោយ អំពីសេចក្តីប្រាថ្នារបស់ពួកគេ ទាក់ទងនឹងទំនួលខុសត្រូវ ប្រវត្តិសាស្ត្រ និងសាមគ្គីភាពនៅក្នុងសង្គម

### តើមានអ្វីនៅក្នុងមជ្ឈមណ្ឌលធនធានចល័តនោះ?

- ឯកសារសាធារណៈសម្រាប់មនុស្សគ្រប់វ័យ ដើម្បីយល់ដឹងអំពីសារៈសំខាន់នៃអតីតកាល
- មានមន្ត្រីដែលជាក្រុមផ្សព្វផ្សាយព័ត៌មាន ទៅជួយ និងឆ្លើយសំនួរអ្នករាល់គ្នា
- ការរៀបចំព្រឹត្តិការណ៍, បទបង្ហាញ, សកម្មភាព និងកិច្ចពិភាក្សាផ្សេងៗ



ជួបគ្នានៅតាមផ្លូវ!

# ការផ្សព្វផ្សាយ

## ការផ្សព្វផ្សាយព័ត៌មាននៅក្នុងសង្គម

### ព័ត៌មានសំខាន់ៗ

ដំណើរការនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

ការជំនុំជម្រះក្តី និងការងាររបស់ អ.វ.ត.ក.

បរិបទប្រវត្តិសាស្ត្រ

ឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយខ្មែរក្រហម

### ខ្លឹមសារសំខាន់ៗ

- សារៈសំខាន់នៃការផ្តល់យុត្តិធម៌សម្រាប់ឧក្រិដ្ឋកម្មនៅក្នុងអតីតកាល
- ចំណេះដឹង និងការអប់រំ គឺមានតម្លៃបំផុត ដើម្បីការពារការកើតឡើងវិញនូវអំពើឃោរឃៅទាំងឡាយ។

គាំទ្រដល់ជនរងគ្រោះ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី





ទស្សនកិច្ចសិក្សា

ប្រជាជនកម្ពុជាច្រើនជាង ៦៦០ ០០០ នាក់បានចូលរួមក្នុងកម្មវិធីទស្សនកិច្ចសិក្សានិងផ្សព្វផ្សាយតាមរយៈបទបង្ហាញនៅតាមសាលារៀន និងការបញ្ចាំងភាពយន្ត!



មាតិកាអប់រំ



កិច្ចសន្ទនាអន្តរជំនាន់



អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

## កំណត់ចំណាំរបស់ខ្ញុំ

កាលបរិច្ឆេទ: / /

កំណត់ចំណាំរបស់ខ្ញុំ